# បញ្ចេញមតិរបស់អ្នក! ការស្ទង់មតិមាតាបិតា និងអ្នកថែទាំ ស្តីពីការអប់រំតាមការយល់ព្រម - ឥឡូវនេះបើកហើយ

ការយល់ព្រមគឺជាការនិយាយថា បាទ/ចាស ចំពោះអ្វីមួយដែលកំពុងកើតឡើង ឬយល់ព្រមធ្វើអ្វីមួយដោយសេរី ដោយគ្មានការភ័យខ្លាច បង្ខំ ឬគាបសង្កត់។

អតីតសិស្ស និងសិស្សបច្ចុប្បន្ននៅទូទាំងរដ្ឋ កំពុងអំពាវនាវឱ្យមានការកែលម្អកាន់តែប្រសើរឡើង ដល់ការអប់រំតាមការយល់ព្រម។

ញត្តិថ្មីមួយធ្វើឡើងដោយអតីតសិស្សក្រុង Sydney, Chanel Contos បាននាំឱ្យយុវជនរាប់ពាន់នាក់ ចែករំលែកសាច់រឿងរបស់ពួកគេ អំពីការឃើញហេតុការណ៍ពិត ឬជួបប្រទះការយាយីផ្លូវភេទ ការរំលោភបំពាន និងអំពើហិង្សាក្នុងចំណោមយុវជន។ នេះបានបង្កឱ្យចាប់ផ្តើមការអំពាវនាវ ឱ្យមានការអប់រំតាមការយល់ព្រមបានមុនពេល និងកាន់តែល្អប្រសើរសម្រាប់សិស្ស។

ក្រសួងអប់រំរដ្ឋ NSW (Department) បានប្តេជ្ញាធ្វើការរួមគ្នាជាមួយឪពុកម្តាយដើម្បីកែលម្អ ការអប់រំដែលមានការយល់ព្រម។

យើងចង់ស្តាប់ឮទស្សនៈរបស់អ្នក។ សូមប្រាប់យើងពីអ្វីដែលអ្នកគិតឃើញ ដោយបំពេញការស្ទង់មតិមាតាបិតាអនាមិកខ្លីខាងក្រោម៖ Consent education survey link

ការស្ទង់មតិនេះមានជាភាសាអង់គ្លេស និង 10 ភាសាផ្សេងទៀត ហើយនឹងចំណាយពេលតិចជាង 10 នាទីដើម្បីបំពេញ។ វានឹងជួយឱ្យ Department យល់ដឹងពីអ្វីដែលឪពុកម្តាយ និងអ្នកថែទាំដឹងអំពីការអប់រំតាមការយល់ព្រម នៅសាលារៀននាពេលបច្ចុប្បន្ននេះ ហើយថាតើធនធានប្រភេទណាដែលនឹងជួយពួកគេ និយាយអំពីការយល់ព្រមជាមួយកូនៗ និងយុវជនរបស់ពួកគេនៅផ្ទះ។

លទ្ធផលសរុប នឹងបានចែករំលែកនៅលើគេហទំព័ររបស់ក្រសួងអប់រំរដ្ឋ NSW នៅចុងឆ្នាំនេះ៖ Consent education website

Department ចង់ស្តាប់ឮពីឪពុកម្តាយ និងអ្នកថែទាំសិស្សសាលារៀនរដ្ឋក្នុងរដ្ឋ NSW មកពីសហគមន៍ទាំងអស់។ រួមគ្នា យើងអាចជួយកូនៗ និងយុវជនរបស់យើង បង្កើតទំនាក់ទំនងប្រកបដោយសុខភាពល្អ។

**សូមបញ្ចេញមតិរបស់អ្នក ដោយបំពេញការស្ទង់មតិឥឡូវនេះ។ សូមចូលទៅកាន់** Consent education survey



NSW GOVERNMENT